# តារាងសង្ខេបអំពីកាតព្វកិច្ចសារពើពន្ធកាតព្វកិច្ចសារពើពន្ធ

# សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញនៅកម្ពុជា

| **កាតព្វកិច្ចសារពើពន្ធ** | **ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត** ( **មាត្រា/ លេខ** ) | **ឯកសារយោងនិងកាលបរិច្ឆេទ** |
|---|---|---|
| 1. កាតព្វកិច្ចចុះបញ្ជីពន្ធដារ | ប្រកាសលេខ ៤៦៤<br><br>ប្រកាសលេខ ៧០១<br><br>ទម្រង់១០១/ FORM 101 | ប្រកាស ស្តីពីការណែនាំអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចុះថ្ងៃទី១២ មេសា ២០១៨<br><br>ប្រកាសស្តីពី ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពពត៌មានអ្នកជាប់ពន្ធ ចុះថ្ងៃទី ១៤ ខែ សីហា ២០២០<br><br>ពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពពត៌មានអ្នកជាប់ពន្ធ |
| 2. **កាតព្វកិច្ច**ជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានរាល់គណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការ និងការប្រែប្រួលឬផ្លាស់ប្តូរ<br><br>❑ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានរាល់គណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាទៅ ក្រសួង-មហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជី។ | មាត្រា ១០ និង ១៧ | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ |

| | | |
|---|---|---|
| ❑ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃក្នុងករណីមានការធ្វើវិសោធនកម្មលក្ខន្តិកៈ ឬការផ្លាស់ប្តូរទី-ស្នាក់ការ ឬការផ្លាស់ប្តូរតំណែងប្រធាន ឬតំណែងនាយកប្រតិបត្តិ ឬការប្រែប្រួលព័ត៌មានគណនីធនាគារ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃដែលផ្លាស់ប្តូរ ឬប្រែប្រួល ដោយភ្ជាប់មកជាមួយនូវសំណុំលិខិត ដែលបានផ្លាស់ប្តូរ។<br>❑ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សរណៈរួចហើយត្រូវជូនដំណឹង ជាលាយលក្ខណ៍អក្សរអំពីព័ត៌មានរាល់គណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារ ក្នុងព្រះរាជាណាចក្រកម្ពុជា ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជី ។<br>❑ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីមានការផ្លាស់ប្តូរ ទីស្នាក់ការ តំណាង ឬតំណាងប្រចាំប្រទេស ឬការប្រែប្រួលព័ត៌មានគណនីធនាគារ ក្នុងរយៈពេលយ៉ាង យូរ ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃដែលផ្លាស់ប្តូរ ឬប្រែប្រួល ដោយភ្ជាប់មកជាមួយនូវសំណុំលិខិត ដែលបានផ្លាស់ប្តូរ ។ | | |
| **3. កាតព្វកិច្ចប្រកាសបង់ពន្ធ**<br><br>**កាលបរិច្ឆេទកំណត់បង់ពន្ធ(ប្រចាំខែ)**<br><br>❑ ត្រូវបង់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ២០ នៃខែបន្ទាប់សម្រាប់ការដាក់លិខិត ប្រកាសដោយផ្ទាល់ ឬថ្ងៃទី២៥ នៃខែបន្ទាប់សម្រាប់ការដាក់លិខិត ប្រកាសអនឡាញ (E-Filing)<br>❑ សៀវភៅស្តីពីសំនួរដែលសួរញឹកញាប់សម្រាប់ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ( E-Filling For Web Application) | **មាត្រា ១០៩ថ្មី នចសព** | **<u>ច្បាប់ស្តីពីសារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០២៣</u>**<br><br>**<u>សៀវភៅស្តីពីសំនួរដែលសួរញឹកញាប់សម្រាប់ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធ</u>** |

| | | |
|---|---|---|
| **កាលបរិច្ឆេទកំណត់បង់ពន្ធ (ប្រចាំឆ្នាំ)**<br><br>❑ ត្រូវបង់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៖ ៣១ ខែមីនា នៃឆ្នាំបន្ទាប់ (ពន្ធលើប្រាក់ចំណូល)<br>❑ ៣១ ខែមីនា នៃឆ្នាំនីមួយៗ (ពន្ធប៉ាតង់) | | <u>អាជីវកម្មអនឡាញ( E-Filling For Web Application)</u> |
| **4. កាតព្វកិច្ចបង់ពន្ធកាត់ទុកទូទៅ**<br><br>**អត្រាពន្ធកាត់ទុកលើនិវាសនជន**<br><br>❑ អត្រា ១៥% (ការទូទាត់ចំពោះការបំពេញសេវា ចាប់ពី៥០០០០ ម៉ឺនរៀល)<br>❑ អត្រា ១០% ប្រាក់ចំណូលពីការជួលចលន ឬអចលនទ្រព្យ<br><br>❑ អត្រា ៦% ការប្រាក់ដែលធនាគារបង់ឱ្យអ្នកជាប់ពន្ធនិវាសនជនមាន គណនីបញ្ញើមានកាលកំណត់<br>❑ អត្រា ៤% ការប្រាក់ដែលធនាគារ បង់ឱ្យអ្នកជាប់ពន្ធនិវាសនជនមាន គណនីសន្សំគ្មានកាលកំណត់ ។<br><br>**អត្រាពន្ធកាត់ទុកលើអនិវាសនជន (អត្រា ១៤%)**<br><br>❑ ការប្រាក់ សួយសារ ថ្លៃឈ្នួល និងប្រាក់ចំណូលផ្សេងៗ ទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ<br>❑ ការទូទាត់ចំពោះសេវាគ្រប់គ្រង និងសេវា បច្ចេកទេសនានា<br>❑ ភាគលាភ ។ | **មាត្រា ២៥. ថ្មី ចសព**<br><br><br>**ប្រកាសលេខ ១៦៩ សហវប្រក អពដ** | **<u>ច្បាប់ស្តីពីសារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០២៣</u>**<br><br><br>**<u>ប្រកាសស្តីពី ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ចុះថ្ងៃទី២០ ខែ មីនា ២០២៤</u>** |

| | | |
|---|---|---|
| **5. កាតព្វកិច្ចបង់ពន្ធលើប្រាក់បៀវត្ស**<br>**ការគណនាពន្ធលើប្រាក់បៀវត្សរបស់និវាសនជន**<br>❑ តាមអត្រាពន្ធក្នុងសេចក្តីណែនាំលេខ ០១៧ សហវ។<br>❑ ការលើកលែងពន្ធលើប្រាក់បំណាច់អតីតភាពការងារចាប់ពីឆ្នាំ២០២០ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០២០ សារាចរណែនាំលេខ០០២ សហវ អពជ។<br>❑ សារាចរណែនាំស្តីពីការលើកលែងពន្ធលើប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០១៩<br>❑ សារាចរស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែមចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ២០១៦<br>**ការគណនាពន្ធលើប្រាក់បៀវត្សរបស់អ្នកជាប់ពន្ធអនិវាសនជន (អត្រា ២០%)**<br>❑ លើរាល់ការទូទាត់ប្រាក់បៀវត្សជាប់ ពន្ធ ដោយមិនមានការអនុញ្ញាត ឱ្យដកទាយជូទានសម្រាប់ សហព័ទ្ធ ជាមេផ្ទះ និងកូនក្នុងបន្ទុកទេ។ | សេចក្តីណែនាំលេខ០១៧ សហវ<br><br>សារាចរណែនាំលេខ ០០២ សហវ អពជ<br><br>សារាចរណែនាំលេខ ០០៣ សហវ<br><br>សារាចរលេខ០១១សហវ | សេចក្តីណែនាំលេខ០១៧ សហវវ ស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២<br><br>សារាចរណែនាំស្តីពីការលើកលែងពន្ធលើប្រាក់បំណាច់អតីតភាពការងារចាប់ពីឆ្នាំ២០២០ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០២០<br><br>សារាចរណែនាំស្តីពីការលើកលែងពន្ធលើប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០១៩<br><br>សារាចរស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែមចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ២០១៦ |
| **6. ការអនុវត្តអាករលើតំលៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រពន្ធអេឡិចត្រូនិច**<br>❑ សេចក្តីណែនាំស្តីពីស្តីពីការអនុវត្តអាករលើតំលៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចចុះថ្ងៃទី ០៨ ខែធ្នូ ២០២១ | | សេចក្តីណែនាំ ស្តីពីការអនុវត្តអាករលើតំលៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្ម |

| | | |
|---|---|---|
| | សេចក្តីណែនាំលេខ ២០៥២២អពដ | តាមប្រព័ន្ធអេឡិចត្រូនិចចុះថ្ងៃទី ០៨ ខែធ្នូ ២០២១(ភាសាខ្មែរ)<br><br>សេចក្តីណែនាំ ស្តីពីការអនុវត្តអាករលើតំលៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចចុះថ្ងៃទី ០៨ ខែធ្នូ ២០២១(ភាសាអង់គ្លេស) |
| 7. **កាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូល**<br><br>អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ<br><br>❑ ២០% ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយនីតិបុគ្គល។<br>❑ ៣០% ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្រោមកិច្ចសន្យាបែង ចែកផលិតផលប្រេងកាត នឹងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើ អាជីវកម្មធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃ នានា។<br>❑ ០% ចំពោះប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិ គ្រប់គ្រាន់ ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធ។<br><br>**ប្រាក់ចំណូលមិនជាប់ពន្ធ**<br><br>❑ -ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល ឬប្រាក់ចំណូលរបស់ស្ថាប័នរាជរដ្ឋាភិបាល<br>❑ ក-អង្គការណាមួយដែលមានសកម្មភាពស្ថិតក្នុងគោលដៅសុទ្ធសាធ ហើយ គ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផល ប្រយោជន៍ឯកជន។ | ប្រការ៥៦ នៃប្រកាស លេខ ០៩៨ សហវ.ប្រក | ប្រការ៥៦ នៃប្រកាសលេខ ០៩៨ សហវ.ប្រក ស្តីពីពន្ធលើប្រាក់ចំណូល ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ |

| | | |
|---|---|---|
| ❑ ខ- សមាគមណាមួយ ក្នុងករណីដែលប្រាក់ចំណូលមិនត្រូវបានប្រើប្រាស់ ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុន ឬរូបវន្តបុគ្គល។<br>❑ ប្រាក់ចំណូលលើកលែងពន្ធក្នុងកថាខណ្ឌនេះ មិនរាប់បញ្ចូលប្រាក់ចំណូលពីសកម្មភាពដែលមិនស្ថិតក្នុងគោលដៅសុទ្ធសាធរបស់សមាគម ឬអង្គការទាំងនោះទេ។ | | |
| 8. កាតព្វកិច្ចបង់ពន្ធប្រចាំខែ និងប្រចាំឆ្នាំ<br><br>កាតព្វកិច្ចបង់ពន្ធប្រចាំខែ (យឺតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ចំពោះការដាក់លិខិតប្រកាសដោយផ្ទាល់ ឬត្រឹមថ្ងៃទី២៥ នៃខែបន្ទាប់ចំពោះការដាក់លិខិតប្រកាសអនឡាញ E-Filing)<br><br>❑ ពន្ធលើប្រាក់បៀវត្ស<br>❑ ពន្ធកាត់ទុក<br>❑ អាករលើតម្លៃបន្ថែម ( ករណីអង្គការធ្វើសកម្មភាពអាជីវកម្មដោយឡែក)<br>❑ ពន្ធអាករផ្សេងៗ<br><br>កាតព្វកិច្ចសារពើពន្ធប្រចាំឆ្នាំ (យឺតត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់)<br><br>❑ ពន្ធប៉ាតង់ ( ករណីអង្គការធ្វើសកម្មភាពអាជីវកម្មដោយឡែក)<br>❑ ពន្ធលើប្រាក់ចំណូល | ប្រកាសលេខ ៩៦៩ | ប្រកាស ស្តីពីការណែនាំអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចុះថ្ងៃទី១២ មេសា ២០១៨ |
| 9. កាន់កាប់ កត់ត្រា និងរក្សាទុក<br>❑ បញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុនានា ឬទិនានុប្បវត្តិ ដែលបានកំណត់ដោយ បទប្បញ្ញត្តិស្តីពីពន្ធដារ ឬបទប្បញ្ញត្តិដទៃ | មាត្រា៩៨ | ច្បាប់ស្តីពីសារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០២៣ |

| | | |
|---|---|---|
| ❑ រក្សាទុកបញ្ជី ឬឯកសារទាំងនោះ ក្នុងរយៈពេល១០ឆ្នាំ គិតពីដំណាច់ឆ្នាំជាប់ពន្ធ។ | | |
| 10. កាតព្វកិច្ចធ្វើការចុះបញ្ជីអាជីវកម្មដោយឡែក<br>❑ ក្នុងករណីអង្គការ ឬសមាគម មានសកម្មភាពខាងពាណិជ្ជកម្ម ឬឧស្សាហកម្ម ឬអាជីវកម្មផ្សេងទៀតដែលមិនទាក់ទិនដល់គោលដៅ ឬមុខងារជាមូលដ្ឋាននៃការលើកលែងពន្ធរបស់ខ្លួន<br>❑ ប្រាក់ចំណូលដែលបានមកពីសកម្មភាពមិនទាក់ទិនទាំងនោះត្រូវជាប់ពន្ធតាមមាត្រា ២០ នៃច្បាប់នេះ។ | មាត្រា៩ (ចំណុចទី៣) និងមាត្រា២០<br><br>សេចក្តីណែនាំ លេខ ៣០៣៣អពដ | <u>ច្បាប់ស្តីពីសារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០២៣</u><br><u>សេចក្តីណែនាំ ស្តីពីការចុះបញ្ជីសកម្មភាពអាជីវកម្មដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០២០</u> |
| 11. កាតព្វកិច្ចដាក់របាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ<br>❑ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវផ្ញើទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់មិនឲ្យហួសពីដំណាច់ខែកុម្ភៈនៃឆ្នាំបន្ទាប់។<br>❑ ក្នុងករណីដែលទទួលបានការគាំទ្រហិរញ្ញវត្ថុពីម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះត្រូវផ្ញើរបាយការណ៍ខាងលើ ដោយចម្លងចេញពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយ ក្នុងអំឡុងពេល៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ១ (មួយ) ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រមដោយ ចម្លងពីឯកសារដើម ឲ្យបានក្នុងអំឡុងពេល៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម។<br>❑ របាយការណ៍នេះត្រូវតម្កល់ទុកនៅទីស្នាក់ការរបស់ខ្លួនរយៈពេលយ៉ាងតិច៥ (ប្រាំ)ឆ្នាំ។ | មាត្រា ២៥ | <u>ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥</u> |

| | | |
|---|---|---|
| ❑ ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃអាចស្នើសុំរបាយការណ៍ស្តីពីសកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំ ឆ្នាំរបស់សមាគម។<br>❑ អង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវផ្ញើទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ ចម្លងពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយក្នុងអំឡុង ពេល៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយព្រមទាំងគ្រប់ឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ១ (មួយ) ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងពីឯកសារដើមឲ្យបានក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម។<br>❑ ក្នុងករណីចាំបាច់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ អាជ្ញាធរសវនកម្មជាតិ អាចធ្វើការត្រួតពិនិត្យ និងធ្វើ សវនកម្មលើសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល។ | | |